# កំណាយនៅឡសរសី

ឡសរសី មានទីតាំងស្ថិតនៅភូមិសរសី ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ វាមានចំងាយប្រហែល25គ.មត្រង់ពីប្រាសាទអង្គរវត្ត ទៅទិសខាងកើត ឈៀងឥសាន្ត (រូបលេខ១)។ ស្ថានីយ៍ឡសរសីនេះត្រូវបានប្រជាជននៅក្នុងតំបន់ផ្តល់ពត៌មានដល់ក្រុមស្រាវជ្រាវបុរាណវិទ្យារបស់អាជ្ញាធរអប្សរាក្នុងឆ្នាំ១៩៩៥។[១] ក្រោយមក ក្នុងឆ្នាំ២០០៣ លោក សុខ កែវ សុវណ្ណារ៉ា បានធ្វើការសិក្សាស្រាវជ្រាវជាលើដំបូងអំពីផលិតផលកុលាលភាជន៍ និងបច្ចេកទេសនានាដែលគេបានអនុវត្តនៅស្ថានីយ៍ឡនេះ សម្រាប់ធ្វើជាសារណាបញ្ចប់ការសិក្សាបរិញ្ញាប័ត្របុរាណវិទ្យា។[២] តាមរយៈការសិក្សានេះ លោកបានធ្វើផែនទី និងបែងចែកក្រុមឡជា៣ក្រុមគឺ៖ ក្រុមត្រពាំងនាងស្នាយ (មានចំនួន១១ទួលឡ) ក្រុមអូរនាងស្នាយ (មានចំនួន៩ទួលឡ) និងក្រុមទំនប់ថ្មដល់ ដែលមានទីតាំងខាងជើងក្រុមត្រពាំងនាងស្នាយប្រហែល៤០០ម៉ែត្រ (មានឡប្រហែល៧ឬ៨ទួល) (រូបលេខ២)។

**តើហេតុអ្វីបានជាគេជ្រើសរើសយកតំបន់នេះសម្រាប់ផលិតកុលាលភាជន៍?**

ជាការពិតណាស់ ទីកន្លែងមួយដែលគេជ្រើសរើសសម្រាប់រស់នៅ និងធ្វើសិប្បកម្មភាជន៍នោះ គឺវាមានចំនុចពិសេសមួយចំនួន ដូចជា៖

ក. ជាកន្លែងដែលសំបូរនិងផ្តល់នូវរូបធាតុដើម គឺដីឥដ្ឋ។ គេបានរកឃើញថា នៅតំបន់នោះមានដីឥដ្ឋ៣ប្រភេទខុសគ្នា នៅតាមបណ្តោយអូរនាងស្នាយ គឺដីឥដ្ឋម៉ត់ពណ៌សស្ថិតនៅស្រទាប់ដីលើបង្អស់។ បន្ទាប់មក គឺដីឥដ្ឋម៉ត់ពណ៌លឿងស្អិតល្មម។ នៅខាងក្រោមបង្អស់គឺជាដីឥដ្ឋពណ៌ក្រហម ស្អិតខ្លាំង លាយឡំជាមួយនិងកំទេចថ្មបាយក្រៀម។

ខ. តំបន់នេះស្ថិតនៅទិសអាគ្នេយ៍នៃជើងភ្នំគូលេន ដែលផ្តល់នូវប្រភពទឹកទាំងខែប្រាំង និងខែវស្សា។ គេបានស្ថាបនាទំនប់ដ៏ធំមួយប្រវែងប្រហែល៤០០ម៉ែត្រ (ទំនង់ថ្មដល់) ដើម្បីស្ទាក់ទឹកទុក និងមានប្រព័ន្ធប្រឡាយបន្តមកតំបន់ត្រពាំង និងអូរនាងស្នាយ។

គ. ជាប្រភពនៃថាមពល គឺព្រៃ សម្រាប់ប្រើជាអុសក្នុងការដុតកុលាលភាជន៍។

---

[១] អ៊ា ដារិទ្ធ ២០០០:៣៨

[២] សុខ កែវ សុវណ្ណារ៉ា ២០០៣

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

## គោលបំណងនៃកំណាយស្រាវជ្រាវ

វិទ្យាស្ថានណារ៉ាបានធ្វើកំណាយជាលើកដំបូងលើស្ថានីយឡបុរាណក្នុងប្រទេសកម្ពុជា នៅភូមិតានី។[៣] លទ្ធផលក៏បានបង្ហាញយ៉ាងច្បាស់អំពីរូបរាងឡ និងផលិតផលកុលាលភាជន៍នៅស្ថានីយ៍នោះ។[៤] ការស្រាវជ្រាវនិងកំណាយបន្ថែមនៅឡសរសី គឺចង់ដឹងអំពីទំនាក់ទំនង និងភាពខុសគ្នាមួយចំនួនរវាងឡទាំងពីរនេះ៖

.សិក្សាប្រៀបធៀបអំពីរូបរាង និងរចនាសម្ព័ន្ធឡ

.ទំនាក់ទំនងបច្ចេកទេស

.ផលិតផលកុលាលភាជន៍រវាងស្ថានីយឡទាំង២

## កំណាយស្រាវជ្រាវ

ក្នុងឆ្នាំ២០០៤ វិទ្យាស្ថានណារ៉ាបានសហការជាមួយអាជ្ញាធរអប្សរា លើកគម្រោងស្រាវជ្រាវ និងធ្វើកំណាយនៅស្ថានីយ៍ឡសរសីនេះ។ ដោយសារក្រុមឡមានចំនួន៣ ដូចនេះ គេបានជ្រើសរើសយកឡលេខ ក១១ នៅលើទំនប់ខាងត្បូងត្រពាំងនាងស្នាយដើម្បីអនុវត្តការងារនេះ។ ជាដំបូង ក្នុងខែធ្នូ ឆ្នាំ២០០៤ គេបានអនុវត្តកិច្ចការធ្វើផែនទីឋានលេខា លើខ្នងទំនប់ខាងត្បូងនេះ ដើម្បីបង្ហាញអោយច្បាស់ទំហំទួលនីមួយៗ និងស្ថានភាពសណ្ឋានដី (រូបលេខ២៣)។[៥] ក្រោយធ្វើផែនទីឋានលេខារួចហើយ គេពិនិត្យឃើញថានៅលើខ្នងទំនប់ខាងត្បូងនេះមានទួលឡចំនួន៥ គឺទួលក៨ ក៩ ក១០ ក១១ និងក១២។ ក្នុងចំណោមទួលឡទាំងនោះ ទួលលេខ ក១១ នៅមានលក្ខណៈល្អជាងគេ គឺមិនត្រូវបានជីកបំផ្លាញដោយប្រជាជន និងជនទុច្ចរិកទេ (រូបលេខ២៤)។

ការងារកំណាយប្រព្រឹត្តិទៅរយៈ៣ឆ្នាំ គឺពីឆ្នាំ២០០៥ ដល់២០០៧ (រូបលេខ២៥ និងលេខ២៦)។ ប៉ុន្តែកំណាយទាំងនេះមិនបានធ្វើជាប់ និងមានរយៈពេលវែងទេ ដោយកត្តាទីតាំងភូមិសាស្ត្រមានភាពលំបាក ជាតំបន់ព្រៃក្រាស់ និងត្រូវឆ្លងកាត់អូរជាច្រើនដង។

---

[៣] Sugiyama, Hiroshi 2000a.

[៤] Nishimura et al. 2005

[៥] សុខ កែវ សុវណ្ណារ៉ា ២០០៤

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ការងារនេះអាចធ្វើទីបានតែក្នុងខែប្រាំង ពិសេសគឺក្រោយពេលព្រៃរបោះត្រូវបានកាប់ និងដុតចោលដោយអ្នកភូមិក្នុងតំបន់។

**លទ្ធផលកំណាយ**

តាមរយៈកំណាយនៅលើទួលឡលេខក១១បង្ហាញថា រូបរាងរបស់វាគឺមានសណ្ឋានដូចគ្នាទៅនិងរូបរាងឡ A6 នៅស្ថានីយ៍ភូមិតានីដែរ។ ឡនេះបែរមុខមកត្បូង ផ្នែកខាងក្រោយបែរទៅត្រពាំង មានរាងពងក្រពើទ្រវែង កម្ពស់ប្រហែល៩ម៉ែត្រពីខាងលើរហូតដល់ខាងក្រោមនៃកន្លែងដុតភ្លើង (រូបលេខ៧)។ រចនាសម្ព័ន្ធដែលនៅមានសល់ គឺកម្រាលឡ ជញ្ជាំងសង្ខាង ដំបូលខាងលើបាក់គ្របលើកម្រាល់ ហើយត្រូវបានដកចេញពេលធ្វើកំណាយ សសរទ្រដំបូលចំនួន៥ បន្ទប់ដុតអុសរាងមូល មានរន្ធដាក់អុស២ និងរន្ធខ្យល់នៅកណ្តាល១។ ទំហំបណ្តោយរបស់វាខ្លីជាងឡ A6 បន្តិច តែទំហំក្អេងនៃបន្ទប់ដុតភាជន៍ធំជាឡ A6 បន្តិចវិញ។ តាមរយៈកម្រាល់របស់វា ឡនេះត្រូវបានគេស្ថាបនាលើគ្នា២ដង។ ក្នុងការប្រើប្រាស់ចុងក្រោយបង្អស់ រន្ធដាក់អុសខាងឆ្វេងត្រូវបានគេបិទចោល។ នៅផ្នែកខាងលើបង្អស់មានក្បឿងផ្កាប់ដែលគេរៀបត្រួតគ្នា និងមានចំនួន៣ជុង ហើយត្រូវបានគេគិតថាអាចជាបំពង់ផ្សែង (រូបលេខ៨)។

**ផលិតផលកុលាលភាជន៍**

តាមការសិក្សាដំបូងរបស់លោកសុខ កែវ សុណ្ណារ៉ា បានរកឃើញថា ស្ថានីយ៍ឡសរសីនេះមានផលិតភាជន៍រហូតទៅដល់១៤មុខខុសៗគ្នា (រូបលេខ៩ និងលេខ១០) រួមមាន៖ ជន្ទាប់ កោដ្ឋ ខួច ពែង ចានក្រឡោម ក្រឡ ឱទិន ផើង ពាង ក្បឿងផ្ងារ ក្បឿងផ្កាប់ ក្បឿងសន្ទឹករកា ក្បឿងរងស្បូវ និងឥដ្ឋ។ ក្នុងពេលធ្វើកំណាយ គេមិនសូវប្រទះបំណែកភាជន៍ទាំងនេះនៅក្នុងឡទេ ភាគច្រើនគេបានមកពីការប្រមូលតាមកន្លែងគេជីកបំផ្លាញ និងមួយចំនួនទៀតពីរណ្តៅដែលគេចាក់ចោលបន្ទាប់ពីដុតរួចហើយមានការបែកបាក់។ គេពិនិត្យឃើញថា ផលិតផលភាជន៍នៅឡសរសីនេះមានលក្ខណៈស្មើដូចគ្នាជាមួយនិងភាជន៍នៅឡតានី ប៉ុន្តែខុសគ្នាត្រង់គុណភាព និងពណ៌ (ទាំងដីឥដ្ឋ និងស្រទាប់រលោង)។ ភាជន៍នៅឡសរសីមានគុណភាពល្អជាង មានសភាពរឹងខ្លាំង ស្រទាប់រលោងជាប់ស្អិតល្អ (នៅឡតានីភាគច្រើនរបក)។ នៅឡតានីដីឥដ្ឋមានតែ២ប្រភេទទេ គឺពណ៌ប្រផេះ និង

ពណ៌ក្រហម។ រីឯនៅឡសរសី ដីឥដ្ឋមានយ៉ាងតិចណាស់៤ប្រភេទ គឺពណ៌ស ពណ៌ប្រផេះ ពណ៌លឿង និងពណ៌ក្រហម។ ស្រទាប់រលោងដែលគេប្រើលើភាជន៍នៅឡសរសីមានពណ៌បៃតងទឹកដោះគោ ពណ៌បៃតងខ្ចី ពណ៌បៃតងចាស់ ពណ៌លឿងចំបើុង និងខ្លះទៀតស្រដៀងពណ៌ត្នោត (ពិសេសលើក្បឿង)។ ក្រៅពីនេះមានការប្រើទឹកដីឥដ្ឋរលោងពណ៌ក្រហមទំពាំងបាយជូរ នៅលើពែង និងពាងមួយចំនួនដែរ។

## កាលបរិច្ឆេទស្ថានីយ៍

ក្នុងកំឡុងពេលធ្វើកំណាយ គេបានកាត់យកកម្រាល់ឡមួយចំនួនដើម្បីធ្វើការវិភាគបែបវិទ្យាសាស្ត្រ រកអាយុកាលរបស់វា។ គេក៏បានយកកំទេចធ្យូងដែលនៅសល់ត្រង់កន្ទែងដុតអុសទៅធ្វើការវិភាគផងដែរ។ លទ្ធផលជាបណ្ដោះអាសន្ន ស្ថានីយ៍ឡសរសីនេះគឺស្ថិតនៅចន្លោះសតវត្សទី១០ ដល់ចុងសតវត្សទី១១នៃគ្រឹស្តសករាជ។

## ឯកសារយោង


សុខ កែវ សុវណ្ណារ៉ា (២០០៣), *កុលាលភាជន៍ឡសរសី*, សារណាបរិញ្ញាប័ត្របុរាណវិទ្យា, ភ្នំពេញ។

សុខ កែវ សុវណ្ណារ៉ា (២០០៤), *របាយការណ៍ស្តីអំពីការធ្វើផែនទីឋានលេខានៅឡសរសី*, សៀមរាប។

អ៊ា ដារិទ្ធ, (២០០០:៣៨), *សង្ខេបទិន្នន័យថ្មីៗនៃកុលាលភាជន៍ខ្មែរ*, ក្នុង ឧទ័យ, លេខ១, សៀមរាប។

Nishimura et al. (2005), *Tani Kiln Site- A6 Kiln Excavation and Research*, Nara Institute, Japan.

Sugiyama, Hiroshi 2000a. *Report of Joint Research of Angkor Cultural Heritage Protection*, Samurize of excavation at Tani A6


KHMER CIVILIZATION



រូបលេខ១




រូបលេខ២

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ២៣



រូបលេខ២៤



រូបលេខ២៥



រូបលេខ២៦



រូបលេខ២៧



រូបលេខ២៨



រូបលេខ៩



រូបលេខ១០